ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់បី

ខ្សែ ៣

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវែរណើម៉ង្ត

គ្រិ. ឆ្នាំ ១៩៣០

ពុ. ស. ២៤៧២

អ្នកទទួលខុសត្រូវ ជុំ-មៅ

# បញ្ជីរឿង


ទំព័រ

១- សេចក្ដីអធិប្បាយអំពីរូបព្រះពោធិសត្វ អវលោកិតេស្វរ ១ អង្គ នៅក្នុងព្រះបរមរាជវាំង ក្រុងភ្នំពេញ អ្នកស្រីស៊ុយសាន កាប៉ឺឡេស អធិប្បាយ . . . ៦៩

២- មិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែចេញពីបាលី (ត) . . . . . .

៣- គតិលោក ឬច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង (ត) . .

« មិលិន្ទបញ្ហា និង គតិលោកនេះ មិនបានចុះក្នុងនេះទេ ព្រោះមានបោះសៀវភៅដោយឡែកហើយ » . . . . . .

៤- រឿងមហាភារតយុទ្ធ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ ប្រែពីភាសាសៀម . . . . . . . . ៧១

# រូបព្រះអវលោកិតេស្វរៈ

ដែលនៅក្នុងព្រះបរមរាជវាំង នៅក្រុងភ្នំពេញ

## ម៉ាដឺម៉ូអាហ្សែល ការប៉ឺឡែស អធិប្បាយ

*ក្រុមការ ជុំ ម៉ៅ ប្រែជាភាសាខ្មែរ*

---

## អវលោកិតេស្វរ

*នៅក្នុងព្រះបរមរាជវាំង នាទីដែលបាគូរក្សាព្រះខ័នរាជ្យនោះ មានអាសនៈមួយតម្កល់រូបសម្រឹទ្ធិជាច្រើន ៗ ក្នុងបណ្តារូបទាំងឡាយនេះ មានរូបដែលឈរប្រកបដោយដៃ ៨ នោះ ១ អង្គ គឺជារូបព្រះអវលោកិតេស្វរៈ ដែលគេរាប់អានទូទៅក្នុងកាលសម័យក្រុងអង្គរ ព្រោះព្រះពោធិសត្វនេះជាអ្នកទំនុកបំរុង ឧបត្ថម្ភនៃក្រុងនោះឯង ៗ*

*រូបនេះអង្គុយលើបល្ល័ង្ក ដែលមានទំនងជាថាំងសម្រាប់ដំរះមន្ទិល នៅផ្នែកសក់នៃព្រះពោធិសត្វនេះមានព្រះពុទ្ធរូប ១ អង្គនៅចំកណ្តាលពីខាងមុខ ហើយព្រះពុទ្ធរូបនេះមានទូទៅសព្វសារពាង្គកាយ ៗ តាមដែលមានក្នុងចារឹកនានា ក្នុងព្រះពុទ្ធសាសនា ប៉ែកខាងមហាយាននោះថា ព្រះធ្យានិពុទ្ធនេះមកប្រាកដនៅគ្រប់ន្ទកេមនៃព្រះអវលោកិតេស្វរៈ ដ៏ជាព្រះរាជបុត្រដែលទ្រង់បែងមក ៗ ប្រសិនបើសង្កេតឲ្យច្បាស់នៅខ្សែក ក្នុងដៃ ក្នុងជើង ចិញ្ចៀន ម្រាមជើង នោះនឹងឃើញមានព្រះពុទ្ធរូបតូច ៗ*

នៅគ្រប់កន្លែងនៅដើមទ្រូង កំភួនដៃ ខ្នង ភ្នែកគោ ក៏ឃើញមានរូបតូច ៗ នេះដែរ នៅត្រង់ថ្ងាស់ដែលជាចន្លោះនៃចិញ្ចើមទាំង ២ នោះមានភ្នែកទីបី១ទៀត ៗ

ដៃខាងស្ដាំកាន់ខ្សែស័ង្ខ សៀវភៅ ទំពក់ កាំអសនី ហើយខាងឆ្វេងកាន់អាវុធ ដប ផ្កា និងរង្វង់ ៗ ក្នុងតម្បន់អង្គរ គេប្រទះឃើញរូបធ្វើដោយថ្មយ៉ាងធំៗជាច្រើន ដែលមានភាពសណ្ឋានដូចជារូបដែលយើងទើបនឹងពោលខាងលើនេះ ហើយដែលគេសន្មតនាមថា អវលោកិតេ-ស្វរៈមានរស្មី ព្រោះព្រះធ្យានិពុទ្ធលោកមកប្រាកដនៅគ្រប់រន្ធរោមនៃព្រះអវលោកិតេស្វរៈ មានឧបមាដូចជាពន្លឺធ្លុសចេញមកអំពីដួងតារាដូចនោះឯង ៗ

ស៊ុយសាន ការប៉ឺឡែស

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរក្រសេម គន្ធរបនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា

## ប្រែពីភាសាសៀម

## (៣)

---

ភីស្ម ទោណ និងអ្នកធំឯទៀតជាច្រើន កាលក្រឡេកទៅឃើញទ្រៅបទី ក៏ដាក់កក្រុជ្រប់ដោយសេចក្ដីអៀនខ្មាសជួសនាង និងអាសូរដល់នាងជាពន្ទឹក តែ ទុរយោធន៍ អ្នកមាននិស្ស័យរឹង ឥតអាសូរដល់តិចសោះ ស្រែកបង្គាប់ដោយសេចក្ដីវក់ថា ទុស្សាសន ចូលសម្រាតសំពត់នាងចេញឲ្យដល់ស្បែក សម្រាតឲ្យលើងទាំងខ្លួន ឲ្យបងសម្លឹងមើលនាងធីរបស់ខ្លួនយាមអាក្រាតកាយទលនេះម្ដង ។

ការលាមកឥតខ្មាសដូចនេះ ធ្វើឲ្យអ្នកអង្គុយនៅក្នុងទីប្រជុំនោះ បណ្ដាលធុលធ្លូលទោសឡើងតែកល់ ៗ គ្នា ទាល់តែម្នាក់ឬពីរនាក់ក្នុងពួកនោះ យកដៃទៅចាប់ក្ដាប់ដងក្របី ក៏កិរិយាដែលគេយកដៃទៅចាប់ដងក្របី មើលទៅហាក់ដូចជាធ្វើទោសចិត្តរបស់គេ ឲ្យធូរស្រាយទៅបាន ខ្លះបាត់ណៃនក្នុងដើមទ្រូងគ្រាន់បើ ។

ដោយសន្ដានចិត្តជាបុគ្គលពាលច្រោកច្រាក ប្រាសចាកមេត្តា ទុ-ហាសាសន បានចូលទៅពោចពេចសម្រាតសំពត់អាវទ្រៅបទី តាម

បង្គាប់ព្រះជេដ្ឋា ទ្រៅបទីស្រែកថា: ចូរស្តាប់ខ្ញុំម្ចាស់ផង លោកអ្នកធំទាំងឡាយ លោកក៏មានកិរិយានិងបុត្រីដូចគ្នា លោកនឹងបណ្តោយឲ្យស្រីអ្នកមានព្រហ្មចារិយ ត្រូវគេកំហែងលេងនៅមុខអស់លោកដូចនេះឬ ចូលជួយខ្ញុំម្ចាស់ផងព្រះអង្គ ចូលជួយឲ្យរួចអំពីសេចក្តីអាសអាភាសអស់នេះផងព្រះគុណ ស្ងាត់ទៅមួយស្របក់ ទ្រៅបទីស្រែកម្តងទៀតថា ម្តេចស្ងៀមស្ងាត់រាល់គ្នាដូចនេះ គ្មាននរណាមួយក្នុងពួកលោកលើកអង្គុលីឡើងការពារសមានសក្តិនៃស្ត្រីដ៏កេមទ្និលគ្មានេះហើយឬ សេចក្តីល្បីខ្ចរខ្ចាយជាតិរបស់គុរុ កិត្តិគុណចាស់របស់ភារតវង្សសាបសូន្យ អស់ទៅហើយឬ ក្សត្រិយ៍ទាំងឡាយលើកលែងជាអ្នកចម្បាំងហើយឬ ស៊ូនាំគ្នាអង្គុយមើលការលាមកដូចនេះបានឬហ្ន៎ ។

ភីស្ម ក្រោធមុខឡើងក្រហម ទោណា ខាំមាត់ ក្តាប់ដៃប្រុងនឹងដាល់ វិទូរថ្ងូរហឺៗ យកចិត្តជួយ ចំណែកឯ ភីម ជាអនុជយុធិស្ឋិរគ្រវីដំបងស្រែកប្រកាសជាពាក្យស្បថទុកថា នឹងហុតឈាម ទុហ្សាសន ហើយនឹងយកជីវិត ទុរយោធន៍ ឲ្យបាន ដោយដំបងនេះមុខថ្ងៃដែលខ្លួនគេស្លាប់ ។

ទុរយោធន៍ធ្វើឫកសម្តែងអំណាចយ៉ាងសម្បើមដោយមានជ័យជំនះ បែរមកត្រាស់នឹងយុធិស្ឋិរថា ទ្រង់ចូលពោលដោយពិតមកមើល ព្រោះទ្រង់តែងតែពោលពាក្យពិតរាល់វេលា ទ្រង់បង់រាជអាណាចក្រ បងអនុ-

កាត បង់ខ្លួនរបស់ទ្រង់ មិនបង់តែប៉ុណ្ណោះបង់ទាំងមហេសីមកខ្ញុំមែនឬ មិនមែន យុធិស្ឋិរមិនហើបមាត់ បំណែកឯកណា នឹកអស់សំណើចក៏សើចកាក តែភីស្ម អង្គុយសម្រក់ទឹកភ្នែកព្រិចៗ មិនមានពោលថាម្តេចសោះ ។

វេលានោះ ព្រះរៅធ្ឫតរាស្ត្រ កំពុងប្រថាប់នៅក្នុងព្រះរាជវាំងមិនបានទ្រង់ជ្រាបហេតុគេទ ដែលកើតឡើងក្នុងទីប្រជុំរដ្ឋមន្ត្រីនោះឡើយ ព្រាហ្មណាចារ្យទាំងឡាយកំពុងស្វាធ្យាយវេទធម៌វត្តល្ងាច ខណៈនោះទ្រង់ឮសម្លេងសិង្គាល (ឆ្កែចចក) លូក្នុងព្រៃប្រាប់ហេតុអាក្រក់ដែលកើតឡើងក្នុងថ្ងៃនោះ ទ្រង់ក៏ធ្លាក់ព្រះហឫទ័យភ្លុក ព្រះកាយញ័រទ្រិបៗ មួយស្របក់ទៀតទៅដល់ក្រាបទូលប្រវត្តិហេតុតាមដែល ទុរយោធន៍ ក៏ឡើង កាលទ្រង់ជ្រាបហេតុអប្បមង្គលដូចនោះ ហើយក៏ទ្រង់ព្រះកន្សែងត្រាស់ព្រះសូរសៀងញ័ររន្ធត់ថា អាកូនកម្មិ រាធ្វើឲ្យព្រះរាជា ទ្រុបឱបាននូវសេចក្តីអាសអាភាសហើយ ដោយប្រមាថមើលងាយធិតារបស់គេដ៏ជាវិសុទ្ធិកន្យា សុំពាក្យការនារបស់បិតាអ្នកកំពុងតែព្រួយសោយទុក្ខនៅវេលានេះ ចូលអភិបាលការពារភយន្តរាយនៃព្រះជាម្ចាស់ដ៏ជាធំក្នុងស្ថានសួគ៌ តាមដែលបានឮហេតុគេទអាក្រក់នោះចុះ ។

គ្រានោះមានអ្នកនាំស្តេចទៅរកនាងទ្រោបទី ទ្រង់ត្រាស់នឹងនាងថា ម្នាលបុត្រីវិសុទ្ធិពជា នាងជាទីសម្លាញ់ដូចដួងហឫទ័យរបស់បិតុល អនិច្ចា

បុត្ររបស់ធំបានធ្វើសេចក្តីកំហឹងដល់នាងជាមុន នាងចូរឲ្យអភ័យដល់ក ផងចុះ នឹងសុំទោសព្រះជាម្ចាស់លើស្ថានសួគ៌កុំឲ្យធ្លាក់លើត្បូងរបស់ក កយសម្លាញ់របស់ធំ នាងនឹងប្រាថ្នាអ្វីធំនឹងប្រទានឲ្យនាងគ្រប់យ៉ាង ។

ទ្រៅបទីពោលពាក្យថ្វាយជ័យដល់ព្រះរាជា អ្នកទ្រង់នូវមេត្តាគុណ ទទួលសុំសេចក្តីមេត្តាប្រោសជួយឲ្យ យុធិស្ឋិរ រាជស្វាមីរួចពាកការៈជា ទាសៈទ្រង់ក៏ប្រទានឲ្យរួចមួយរំពេចព្រះចៅធ្ឫតរាស្ត្រសុំឲ្យទេវីសម្តែងសេចក្តីប្រាថ្នាយ៉ាងដទៃតទៅទៀត នាងក្រាបទូលសុំឲ្យពុន សេះ រថ អាវុធ របស់គេមកវិញ សេចក្តីប្រាថ្នាគ្រាទីពីរនេះព្រះចៅធ្ឫតរាស្ត្រក៏ទ្រង់ប្រទានឲ្យជាយ៉ាងឆាប់ ហើយសុំឲ្យនាងសម្តែងសេចក្តីប្រាថ្នា គ្រាទីបីតទៅ ទ្រៅបទីក្រាបទូលថា ខ្ញុំម្ចាស់ជាធីតាក្សត្រិយ៍ ខ្ញុំម្ចាស់អស់ប្រាថ្នារបស់ដទៃទៀតហើយ ប្រាថ្នាតែពីរដងប៉ុណ្ណោះក៏ល្មមហើយ នឹងប្រាថ្នាសព្វសារពើមិនគួរព្រះករុណា ។

បាណ្ឌវក្សត្រិយ៍ បានអនុញ្ញាតឲ្យត្រឡប់ទៅក្រុងឥន្ទ្របថវិញ វេលាចេញទៅអំពីក្រុងហស្តិនបុរ ទុរយោធន៍ ក៏ចូលទៅគាល់ព្រះរាជបិតា ទូលបន្ទោសព្រះរាជបិតា ដោយសេចក្តីពិរោធថា ល្អងធុលីព្រះបាទអនុញ្ញាតឲ្យពួកបាណ្ឌវទាំង ៥ រូបទៅជាសុខ គេគិតតែនឹងធ្វើសង្គ្រាមសងសឹកយើង ព្រោះហេតុនោះសុំឲ្យទូលព្រះបង្គំជាខ្ញុំភ្នាល់ស្កានឹងគេមួយគ្រាទៀត ហើយក៏រិតតែដែលនឹងភ្នាល់ម្តងនេះដូចនេះ អ្នកចាញ់តោង

ត្រូវនិរទេសទៅនៅព្រៃកំណត់ ១២ ឆ្នាំ រួចអំពីនោះត្រូវពួនមុខនៅក្នុងទីសន្ដោស ១ ឆ្នាំទៀត យើងអាចនឹងចៀសវាងសឹកសង្គ្រាមបាន ដោយឧបាយយ៉ាងនេះប៉ុណ្ណោះ ។

ព្រះរាជាជាអ្នកមានសន្ដានចិត្តទន់ ក៏បណ្ដោយតាមរាជឱរសស្រាស់បង្គាប់ឲ្យរាជឱរសទៅតាមបាណ្ឌវក្សត្រិយ៍អម្បាលនោះ ត្រឡប់មក ចាប់ផ្ដើមលេងស្កាភ្នាល់ម្ដងទៀត យុធិស្ធិរ និងសកុនិ អង្គុយទល់មុខគ្នាចាប់លេងទៅតាមគម្រិះ ហើយខឹងប្រុងដើងទឹងយកប្រៀបដោយសព្វខ្លួន សកុនិយកកូនស្កាបង្កប់សំណរមកលេងទៀត យុធិស្ធិរក៏ចាញ់ទៅទៀតដូចដែល ក្នុងទីបំផុតព្រះអង្គនឹងអនុភាតាព្រមដោយទ្រោបទី ក៏ត្រូវទទួលសេចក្ដីអបរាជ័យដ៏ជាផលនៃល្បែងស្កា គេនិរទេសចេញចាកនិវេសន៍មហាស្ថាន ។

## ភាគ ៣

### ការនិរទេស បាណ្ឌវក្សត្រិយ៍

បាណ្ឌវក្សត្រិយ៍ បងប្អូនទាំងប្រាំអង្គ ព្រមដោយទ្រោបទីទេវី ត្រូវគេនិរទេសចាកភាក ក៏ស្ដេចនាំគ្នាលីលាចាកក្រុងសន្សឹមៗទៅបែរព្រះភក្ត្រឆ្ពោះសំដៅអារញ្ញប្រទេសដែនព្រៃ ព្រះភក្ត្រស្លុកស្លាំង ព្រះឱស្ឋក្រៀម ព្រះនេត្រអាប់ឥតរស្មី អ្នកដែលប្រទះឃើញស្ដេចតាមផ្លូវ

តាមព្រៃ កំដកដង្ហើមធំពល់ៗគ្នា ស្តេចនាំគ្នាយាត្រាតត្រុកទៅមិនមានចរចា ហាក់ដូចជាថា បើកព្រះឱស្ឋបញ្ចេញទៅសោត ក្រែងហួសកម្លាំងហឫទ័យនឹងទ្រូលទ្រាំទ្របាន នៅវេលាមួយនោះ ទើបមួយអង្គក្នុងពួកនោះ មានបន្ទូលបញ្ចេញមកថា អវដ្តុនក្នុងវាំងនេះទៅទល់នឹងវេលាដែលខ្ញុំបានឃើញក្បាលទុរយោធន៍ដោតនៅចុងព្រះសែងធ្នូនេះ ខ្ញុំនឹងមិនបាននូវសេចក្តីស្ងប់នឹងសុខជាដាច់ខាត ។

សហទេព កំគិតឃើញប្រហែលគ្នា ទើបឆ្លើយថ្លែងសម្តែងប្រណិធានរបស់ខ្លួនទៅថា ខ្ញុំនឹងមិនតម្ងោះធ្នូនេះ ត្រាតែព្រួញធ្នូនេះបានស៊ីសាច់ផឹកឈាម អាចោរកំណាច អម្បាលនោះជាមុនសិន ។

អង្គទីបី អស្សុជលជោកកក្ត្រា មានបន្ទូលឆ្លើយថ្លែងឡើងថា កាលរាមើលឆ្ងាយទ្រៅបទី ខ្ញុំអត់ទឹកភ្នែកមិនបាន តែឥឡូវនេះខ្ញុំតាំងប្រណិធានទុកក្នុងចិត្តថា ខ្ញុំនឹងមិនខ្សឹកក្របីនេះចូលស្រោមវិញ ត្រាតែខ្ញុំបានយកឈាមអាពួកអប្បលក្ខណ៍អម្បាលនោះ មកលាបមុខក្របីជាមុនសិន ។

អង្គទីបួន ទឹកក្តៅក្នុងព្រះហឫទ័យណាស់ ចង់ពោលពាក្យសម្បថទុកជាច្រើនយ៉ាង ទើបលើកព្រះហស្តដំម៉ាំឡើងពោលថា ដៃនេះនឹងមិនសម្រាកឲ្យសប្បាយ ត្រាតែលាងអាពួកកំណាចចិត្តទមិឡ ឲ្យរលីងទៅអំពីផែនធរណី ។

ចំណែកឯយុធិស្ឋិរ មិនត្រាស់ជាដូចម្ដេចឡើយ ដាក់ព្រះភក្ត្រស្រ-
ងូត ខណៈដែលអនុកាតាតាំងសេចក្ដីបណ្ដាំទុកផ្សេងៗគ្នា ព្រះអាការ
មើលទៅស្រងូត ពេញទៅដោយសេចក្ដីផញើងដូចជាមិនដឹងជាមានហេតុ
ការណ៍អ្វីខាងក្រៅ ចំពោះដឹងតែហេតុក្នុងចិត្តប៉ុណ្ណោះ ស្ដេចដំណើរ
ទៅតាមមាគ៌ា ព្រះសិរឱនក្រឡុលរុលតែទៅមុខ ទឹងក្រឡេកមើលនាយ
អាយសោះ ព្រះភក្ត្រដោកទៅដោយអស្សុជល យូរ ៗ ក៏ដកដង្ហើមធំ
ម្ដង ៗ

ឯទ្រោបទីទេវីសោក មើលទៅមុខគួរអាសូរជាងស្ដេចប្រុសៗអស់
នោះ នាងទ្រង់សំពត់អម្បោះ មិនទ្រង់សំពត់អម្បោះនិងទ្រង់សំពត់ព្រៃ
ដូចស្ដេចស្រីក្នុងព្រះនគរ ព្រះកេសារបស់នាងរំលងសំយាកលើស្មាព្រះ
នេត្រាគយគន់មើលតែទៅដី មិនងើបងើយឆាកមើលទៅទិដទៃ ហាក់បី
ដូចជាថា សេចក្ដីអាម៉ាស់មុខដែលនាងបានទទួលមកសង្កត់ហឫទ័យ
មិនអាចនឹងមើលទៅទិដទៃបាន តែចំមើលក៏ទឹងទ្វេចំនួនច្រើនឡើង ៗ

នាងដើរហាលកំដៅថ្ងៃជាកល់ទិក ឥតមានវេលាណាដែលពៅ
ស្រួល ត្រូវតែកំដៅសូរ្យរង្សីគ្មានអ្វីបិទបាំងព្រះសិរ ឲ្យស្រទន់អស់ក្ដៅក្នុង
អង្គ កន្ត្រងរបស់នាងត្រូវខ្យល់បក់បោកមកតាមផ្លូវ ក៏គ្រៀមក្រស់
អស់ពណ៌ លុះចូលវេលាសន្ធ្យាពេលត្រជាក់ ទឹកសន្សើមក៏ធ្លាក់បំ
ព្រំបីដូចជាស្រប់ស្រោចកន្ត្រនាង ហូរហៀរហោមលាយគ្នានឹងអស្សុជល

ឆាក  នាងខំយាត្រាតាមព្រះភស្តាមុខគួរវេទនាមាលព្វាយ  ។

ដើរផ្លូវទៅគ្រានោះ  កាលកន្លងទៅក៏ច្រើនទិវារាត្រីក្នុងទីបំផុត  ក៏បានដល់ព្រៃធំ ១ ឈ្មោះថា កនកវ័ន  ក្នុងព្រៃនោះងងឹតណាស់ណា  នាំឲ្យច្រងំសម្គាល់ទៅថា  យប់សន្និយាមកដល់ឆាប់ខុសប្រក្រតី ដើមប្រឹក្សាក្នុងព្រៃនោះដុះជិតជិតគ្នា  កម្រព្រានព្រៃណានឹងជ្រៀតដើរចូលទៅបាននរណាមួយឈានចូលទៅហើយ  ដែលមិនត្រូវបន្លាមុត - ឆ្កត់  ឬប៉ាស់នឹងដើមឈើនោះគ្មានដែលលំបាកជាងនេះទៅទៀត  ក៏គឺផ្លូវក្នុងព្រៃនោះពេញទៅដោយដុំថ្ម ធំតូចរដិបរដុបទំគិច  ជំពុបប៉ាស់ព្រះបាទក្សត្រិយ៍បង្អួនអម្បាលនោះរហូតទៅ  ជួនកាលជជ្រុលជជ្រកបោកប៉ះទៅលើឈើ លើថ្ម  ជួនកាលក៏ភ្ញាក់ធ្លាក់ទៅក្នុងជង្ហុក  ព្រះបាទដែលទន់ត្រសួលពល់ៗអង្គ  ក៏ដាច់ដោចរលាត់ដាំដាំខ្លួចខ្លួមិនមានទីស្រួលត្រង់ណា  ពោះបីម៉ោះក្តី  ព្រៃធំត្រពៃឈើនោះបានជាទីអាស្រ័យមួប  មួយយ៉ាងមិនត្រូវកំដៅថ្ងៃថែងចាំង  ព្រោះបាំងទៅដោយស្លឹកឈើតែទាំងពីរយ៉ាង  កម្រនឹងវិនិច្ឆ័យទៅថាយ៉ាងណាលំបាកជាងយ៉ាងណា  ព្រោះកំដៅថ្ងៃក៏ដុតកំដៅកាយឲ្យក្រៀមក្រស់ភាប់អស់កស៍  បន្លាសោតក៏មុតធ្លក់រលាត់ដាច់សាច់ចេញឈាម  ។

ទីនោះតែពេលប់ព្រិលៗ ក៏ងងឹតដូចជាយប់ជ្រៅទៅហើយ  ពត្រីសត្វក៏ចេញពាក់អំពីទីលំនៅយាសយំទ្រហឹង  តាមភេទភាសា  គោចរ

រកស៊ីក្នុងព្រៃធំសមសាន បាណ្ឌវក្សត្រិយ៍ត្រូវគេនិរទេសចាកនិវេសន៍វាំង ជ័យ តាំងដើរព្រៃមកដល់ត្រង់នេះ តាំងប្រទះនឹងភ័យក្នុងព្រៃមុខគួរស្ញែងនេះម្តងទៀត ត្រង់ផ្លាស់ប្តូរគ្នាទៅចាំយាម ប្រយ័ត្នការអន្តរាយឲ្យរាល់ៗអង្គ មានវេលាផ្ទុំសម្រាកព្រះកាយបានមួយស្របក់ ៗ មួយអង្គគ្រាន់មានកម្លាំងទឹងចេញដើរទៅពីព្រលឹម ផ្ទុំបន្តិចបន្តួចយ៉ាងគេរត់ភ័យ បានធ្វើវត្តិសម័យឲ្យកន្លងទៅរហូតដល់ក្តីដោយប្រការដូចនេះ ។

លុះព្រឹកឡើង បាណ្ឌវក្សត្រិយ៍នៅទ្រាំនៅឡើយ ព្រោះក្នុងអរញ្ញប្រទេសនោះងងឹតសូន្យសុង គ្មានពន្លឺលេចចូលទៅប្រាប់ម៉ោងវេលា មិនឃើញខែមិនឃើញផ្កាយ ជាគ្រឿងសម្គាល់ឲ្យដឹងរាត្រីកាល ថាគោ-ចរទៅហើយបានប៉ុណ្ណោះប៉ុណ្ណោះយាមប៉ុណ្ណោះប៉ុណ្ណោះនាឡិកា សង្កេតដឹងបានតែដោយអាស្រ័យសម្រែកសត្វព្រៃ បាណ្ឌវក្សត្រិយ៍ដើរដេកនៅក្នុងព្រៃគគរនោះ ទំរាំតែលេចចេញរាល់កំប្រើទទឹករាត្រីតែជាប៉ុន្មានយប់ប៉ុន្មានថ្ងៃទ្រង់ចាំមិនបាន ព្រោះទៀយយ៉ាកលំបាកព្រះកាយពល ដោយគ្រេចរិលរលាក់ក្នុងព្រឹក្សព្រៃអស់កម្លាំងល្ហិតល្ហៃ ព្រះហឫទ័យស្រុលទៅតាមគ្នា ទាល់តែក្លែបគិតនឹកដល់រឿងថ្ងៃ-ខែដែលកន្លងទៅ ដែលចាំបានខ្លះក៏ស្រពិចស្រពិល ។

ថ្ងៃនោះ ទ្រង់តើនឡើងហើយ កំនាំគ្នាដើរឆ្ពោះសំដៅទៅទិសលើ មានមួយថ្ងៃនោះ ក៏ទៅដល់ជាយព្រៃ ទៅដល់ដោយមិនទាន់ដឹង

ខ្លួន បានឃើញពន្លឺធ្លុះមកខាងមុខក្នុងរយៈឆ្ងាយប្រហែលគ្នានឹងពន្លឺដែល ធ្លុះចូលទៅក្នុងអណ្ដូងដ៏ជ្រៅ ទ្រង់មានសេចក្ដីសង្ឃឹម និងជួរក្នុងហឫទ័យ តែកល់ៗអង្គ ក៏នាំគ្នារួតរះដើរសំដៅទៅត្រង់ពន្លឺនោះ មួយស្របក់ក៏ចេញផុតអំពីព្រៃធំ ទៅដល់ទីដែលឃើញពន្លឺអំពីចម្ងាយ ទីនោះជាទីវាលខ្សាច់ធំ ឥតមានព្រឹក្សាសូម្បីមួយដើមដុះនៅទីនោះសោះឡើយ ការដែលទឹងដើរកាត់វាលខ្សាច់ទៅនោះ ជាការលំបាកមិនតិច ទឹងទៅបានក៏តែសត្វឧដ្ឋដែលជាសត្វធន់ជា សម្រាប់បាណ្ឌវក្សត្រិយ៍ ឃើញជាលំ-បាកជាងដើរក្រុលក្នុងព្រៃទាំងដប់ភាគជាប្រាកដ ព្រោះថាទ្រង់មានរាងកាយទន់ល្ហេងល្ហើយស្បើយបេកម្លាំងដោយដើរផ្លូវមកជាយូរថ្ងៃណាស់ហើយ កំដៅថ្ងៃសោតក៏ក្ដៅដល់ទីទឹងដាក់ជើងសម្ទុស្បដំស្ទើរពុំបាន លំបាកជាងដើរក្នុងព្រៃទាំងដប់ភាគ ពន្លឺព្រះអាទិត្យចែងចាំងមកគ្រាប់គ្រួស ប្ដូតូចៗក៏ចែងចែកជារស្មីធ្លុះព្រោត ៗ ចាំងចូលក្នុងចក្ខុបីដូចជាកញ្ចក់ត្រូវរស្មីព្រះអា-ទិត្យ ធ្វើឲ្យងងឹតព្រិលដើរពុំបាន សេចក្ដីក្ដៅធ្វើឲ្យកើតស្ងួតកស្រេកទឹក ឯរឿងទឹកផឹកក្នុងទីនោះក៏រកគ្មានឃើញទំនងថានឹងមានត្រង់ណានោះឡើយ ទ្រង់សម្គាល់ក្នុងព្រះហឫទ័យថា មុខជានឹងដួលដាច់ខ្យល់ស្លាប់ ក្នុងកណ្ដាលវាលនោះជាមិនខាន ព្រោះអស់ព្រះកាយពលល្ហិតល្ហៃពេញបន្ទុកមកហើយ ក្រែងទឹងលើកជើងឈានដើរទៅទៀតពុំរួច ដើមព្រៃព្រឹក្សារុយៗដែលមាននៅទៀបទីនោះសោត ក៏មិនជាទីត្រជាក់

ដូចក្នុងព្រៃធំ ព្រះពាយបក់បោកដោយតាំងកំដៅថ្ងៃ មកប៉ះពាល់ កក្រើកស្លឹកក្រៀម ក៏របើកតែក្រំក្រៀមស្វៀមណាស់ទៅទៀត ទោះបីម្ល៉ោះក្ដីទ្រង់ក៏បបួលបងប្អូនព្យាយាមដើរឆ្លងកាលខ្សាច់ ឬហៅថា ទន្ទេ-ខ្សាច់ទៅទាល់តែព្រលប់ទៀបយប់អស្ដង្គត វេលានោះទ្រង់បានឃើញអាស្រមមួយខ្នងតូច មានព្រៃឈើនិងស្រះទឹកថ្លានៅជាខាងកើតជាទីត្រ-ជាក់ត្រជុំសប្បាយ ល្មមនឹងបំបាត់ទុក្ខវេទនាដែលនឿយព្រួយមកតាមមាគ៌បានខ្លះ ទើបទ្រង់ដើរចូលទៅកាន់ទីនោះសំចតនៅក្នុងអាស្រម និងអាស្រ័យទឹកនៅក្នុងស្រះនោះគ្រាន់នឹងក្សាជីវិតទុក ១ គ្រាសិន ។

អាស្រមនោះ តាំងនៅក្នុងញកភ្នំហិមាល័យ បាណ្ឌវក្សត្រិយ៍តាំងព្រះហឫទ័យនឹងអាស្រ័យនៅក្នុងអាស្រមនេះរហូតកាល ១២ ឆ្នាំ តាមកំ-ណត់និរទេស មានភ្នំបែបជាបរិវេណព័ទ្ធជុំវិញ ពាសពេញទៅដោយព្រឹក្សាលតាជាតិផ្សេងៗ ជាដង្គមគ្រប់គ្រសាយសាខា ដារយ៉ាំរយោលរយោងយោន ។ រាងតាំងស៊ុំទ្រុមគុម្ពឈើស្លឹកជិតងងឹតស្លូនស្រស់ មុខគួរខ្លាចព្រឺព្រួច ព្រោះនោះឯងធម្មជាតិគាត់តែងឡើង ដូចនេះ មិនដែលមានមនុ-ណាភាបសានទះពីចូលទៅកាប់កាត់ឈើព្រៃនោះសោះឡើយ តាំងពីណាៗមកហើយ មិនដែលឮលឺខ្ទមនុស្សណាមួយ ដើរចូលទៅវីវក្នុងមហាវ័ននោះដល់ម្ដងឡើយរហូតរៀង ព្រៃព្រឹក្សានោះចេះតែលូតលាស់ខៀវស្រស់ជាធម្មតា ក្លាយជាទីទស្សនាថៃអ្នកដែលបានទៅយល់

ឬមួយវិញទៀត គួរហៅថាជាទីត្រជាក់ក្អែក ក្នុងគិម្ហរដូវក៏មិនសូវក្តៅ ពេក ក្នុងហេមន្តរដូវក៏មិនសូវរងាណាស់ តែយកស្រួលបំផុតក្នុងវស្សន្ត-រដូវត្រូវភ្លៀងធ្លាក់ជាទីត្រជាក់ត្រជំជាងរដូវទាំងពួង មេឃមិនបិទបាំងសូរិ-យាកាស រមែងឲ្យកើតស្រទំស្រទន់ត្រជាក់អាកាសធាតុ ទាំងម្លប់ដោយ ស្លឹកព្រៃព្រឹក្សាជាតិអំបាលនោះបាំងខាំងខណ្ឌមួយជាន់ទៀត ក៏រឹតតែធ្វើឲ្យ ត្រជាក់ផែនពសុធា មានទាំងសទ្រើម ទឹងទឹកភ្លៀងធ្លាក់រៀងៗរ៉ុយៗ ប្រ-ប្រយចុះមក ប្រស់ព្រំលើគុម្ពឈើតូចធំទាំងឡាយ ត្រិណជាតិបាន ទទួលសេចក្តីត្រជាក់ត្រជំនៃធម្មជាតិ ក៏លូតលាស់ខៀវស្រស់ងងឹតជាស ទៅទាំងផ្ទៃធរណី មើលទៅគួរជាទីទស្សនា គល់បឺដូចជាព្រំចៀមធំ ដែលបុគ្គលយកទៅក្រាលទុកនៅទីនោះ មានទាំងហ្វូងសត្វចតុបាទយំ គឹកកងរំពងព្រៃ ប្រឡូលហើយទៅដោយសម្លេងបក្សីយំប្រៅប្រាវអឺងអាប់ ទាំងផែនវនាល័យ ពនពីរនោះមានទាំងជ្រលងជងភ្នំ ទឹកហូរចុះទៅ តាមបន្ទោះថ្ម ឮសូរទឹកឈួៗ ឆរៗ ដោយអន្ទើៗ ទីខ្លះក៏ហូរហាក់ទៅប៉ះ លើផែនសិលាខ្មារាគ្រាប់ប្រប្រុយហុយជាផ្សែង ដូចកាលហូរប៉ះទៅលើ ផែនថ្ម ហើយហូរចុះទៅក្បាំងៗ ក្លុងៗ ប្រុសខ្លួនជាអន្ទង់ទិសអាង ផុតពី នោះទៅក៏ហូរសាចពាចជ្រួតជ្រាបទៅតាមគុម្ពឈើ គល់ព្រឹក្សាទាំងឡាយ សម្រាប់ដប់លៀងព្រឹក្សលតាជាតិទាំងពួង ឲ្យល្អខៀវស្រស់ជានិច្ចកាល រដូវកាល ន័យថាព្រៃនោះជាទីអាស្រ័យនៅនៃទេពារក្សទាំងឡាយ ដូច

កាលមើលទៅប្រហែលហាក់ភាពចម្ងន់នៃនិរយភូមិជាពន្ទឹក មុខគួរព្រឺ ព្រួចក្នុងកោមលហឫទ័យ ។

ទីបំផុតនៃការដើរព្រៃនៃបាណ្ឌវក្សត្រិយ៍ ក៏ឈប់ត្រឹមនេះឃើញសមគួរតាមកំណត់ការសញ្ញានិរទេសហើយ បាណ្ឌវក្សត្រិយ៍បានអាស្រ័យនៅក្នុងព្រៃនោះ ១២ ឆ្នាំ ពេញតាមកម្រិតអាស្រ័យផ្លែឈើ មើមឈើបន្លែព្រៃនិងសាច់សត្វ ដែលទ្រង់ថ្លឹងសរបានមកជាអាហារចិញ្ចឹមជីវិត ។

នាថ្ងៃ១ នោះក្នុងពេលដែលនៅព្រៃ គេជុំគ្នាគិតដល់រឿងដើម ទើបនិយាយចេញមកថា ខ្ញុំនៅមានសេចក្ដីឆ្ងល់ថា មនុស្សណាមួយនឹងមានសេចក្ដីក្រៃក្រៀម ទុក្ខព្រួមដូចយើងខ្ញុំខ្លះ យើងត្រាច់ត្រាកបាកព្រះនគរបាកសម្បត្តិ និងគណញាតិតូចធំទាំងឡាយ រាល់ៗ ថ្ងៃដែលកន្លងទៅមានតែទុក្ខសេចក្ដីសោកសៅរបស់យើងឲ្យពេញពោរឡើង ប៉ុន្តែជាថាបេះតែបន្ថែមទុក្ខសោកមកលើយើងឲ្យក្រៀវជានិច្ចនិរន្តរ៍ ។ កាលនាងទ្រៅបទីទើបចូលមកក្នុងទីប្រជុំ ហើយត្រូវគេចាប់សម្រាតសំពត់នាងផ្ចាញ់ផ្ចាលឲ្យយើងអាម៉ាស់មុខអ្នកតូចអ្នកធំទាំងពួង ការប្រមាថមើលងាយគ្នាក្នុងទីប្រជុំជនដូចនេះ ឈ្មោះថាប្រមាថដោយព្រហ្មាន ពួលចិត្តស្ត្រីដែលពេញទៅដោយសេចក្ដីអៀនខ្មាសនឹងទប់ទល់បាន យ៉ាងនេះទើបនឹងត្រាំបានឬ កើតទុក្ខគ្រានោះ ខ្ញុំក៏មិនប្រែបលអាពួកកំណាចអស់នោះឲ្យរួចទៅតែអនិច្ចា ទាល់តែស្ទើរនេះមកហើយ នឹងទៅការកយករឿងដែលកន្លង

ទៅហើយមកនិយាយ តើនឹងមានប្រយោជន៍អ្វី ។

គឹម បានឮដូចនោះទើបនិយាយផងថា មិនតែប៉ុណ្ណោះ ការដែលលេងភ្នាគ្រាក្រោយបំផុតនោះ មិនតែធ្វើវិបរណោរបស់យើងឲ្យងងឹតទៅប៉ុណ្ណោះ វាធ្វើទាំងចក្ខុរបស់យើងឲ្យងងឹតទៅផង ក្នុងខណៈនោះយើងឃើញផលអាក្រក់បានក្រឡែត ៗ យើងក៏នៅតែភ្នាល់នឹងគេ ទាល់តែពោះពេងលើងដូចជាគង ឥឡូវនេះនឹងជាប្រយោជន៍អី ដែលមកយំស្ដាយទឹកដោះដែលកំពប់អស់ទៅហើយ ។

អើ ក៏កាលខត្តិយរាជលើកលែងត្រង់សច្ចុ និងធម្ម ហើយទៅប្រ-ព្រឹត្តកន្ទបខដែលវិន័យហាមមិនឲ្យប្រតិបត្តិ ក៏បានឈ្មោះថា ទ្រង់លើកលែងជាក្សត្រិយ៍ត្រង់រាជ្យ គម្ពីរប្រកាសមកថា រាជសម្បត្តិនិងរាជអាណា-ចក្រនៃខត្តិយរាជនោះ រមែងត្រូវគេរឹបយកខ្លួនខត្តិយរាជនោះ ៗ សោតក៏រមែងអានុភាពនោះធ្វើទោសឲ្យត្រង់ជីវិតដោយបទសន្តោស មានអាការដូចជាអ្នកទោសដែលគេនិរទេស ឲ្យទៅនៅព្រៃព្រោះហេតុតែល្បែងខត្រង់នេះក្នុងព្រះគម្ពីររបស់យើង ពោលទុកថា ការលេងភ្នាល់ជាការបាបមិនដូចនោះឬ ឥឡូវយើងបានទទួលវិបាក សមតាមគម្ពីរពោលទុកមែនឬទេ យើងខូចព្រះនគរខូចឥស្សរភាព ខូចសព្វសារពើគង់នៅតែជីវិតដែលរកកិត្តិយសគ្មានសោះប៉ុណ្ណោះ យើងទៅអ្នកភ្នាល់នឹងគេមិនមានគិតអស់ប៉ុន្មានអស់ទៅ បេះតែកើបកោយចាក់ទៅចាល់លើងក្រើង ហ្នឹងគឺសេច

កិច្ចការបស់យើង មិនមែនឬ ឥឡូវយើងជាប់នៅក្នុងផុកផុរហើយ មិនមែនឬ តែជារឿងដែលកន្លងទៅហើយ មិនគួរនឹងនាំយកនិយាយថ្មី ឲ្យតែហែកពពុះមាត់ឥតអំពើ យើងធ្វើខ្លួនយើងមិនស្រួលឯង ឲ្យមនុស្សទាំងលោកសើចឡកឡឺយបាន ។ បន្ទាបខ្លួនចូលទៅលេងល្បែងស្កា ទាល់តែចាញ់អស់ទ្រព្យធនធាន ហើយមិនស្កប់ ថែមទាំងព្រមឲ្យគេនិរទេសខ្លួនព្រោះល្បែងនោះផងទៀត ។ សញ្ញាការនិរទេសពួកយើងនេះ វាធ្ងន់ខ្លួនពេកណាស់ ចង់តែយើងមាំពេករើខ្លួនមិនរួច ស្មើដូចជាឲ្យទៅស្លាប់ក៏ជាបាន ។

នកុល កាលបានស្ដាប់ភីម អភិប្រាយសព្វ។ ក៏ទ្រង់ព្រះកន្សែងដោយមករំពឹងដល់ហេតុការណ៍ដែលកន្លងទៅហើយ និងហេតុការណ៍ទៅខាងមុខ ដែលនឹងត្រូវបានប្រសព្វក្នុងថ្ងៃតៗទៅ ទ្រង់ឈឺចិត្តជាបំផុត ទើបមានបន្ទូលថា ឱគ្រោះគ្រោះថ្នាក់វិបត្តិសាត់មកដល់បុរសឯណា និមួយឃុំសតិទុកបាន នឹងពោលទូកដែលកំពុងលិចមុនរបស់ដៃ តែនោះវាអស់ផ្លូវកែខៃហេតុការណ៍ដែលកំពុងប្រព្រឹត្តទៅហើយ វៀរលែងតែសាប់របស់គេ ។

សហទេពថែមមកទៀតថា ឱព្រះ សម្ដេចដែលទ្រោបទីប្រកួន បន្ទប់ប្រជុំរដ្ឋមន្ត្រីនោះ វាឮជាប់ត្រចៀកដល់សព្វថ្ងៃនេះ ព្រះទេវីត្រាស់ត្រូវច្បាប់ហើយ ព្រះរាជស្វាមីរបស់នាង ធ្លាក់ទៅក្នុងឋានៈជាទាសា

ហើយ រមែងគ្មានអំណាចតាមផ្លូវច្បាប់ដែលនឹងលក់នាង ឬនឹងយកនាងទៅដាក់ភ្នាល់ ម្ដេចយើងមិនលើកច្បាប់ត្រង់នេះឡើងជជែក ហើយសុំឲ្យការដំណើរទៅតាមនោះ តែគ្រានោះកំពុងជ្រួល ទាំងគេទាំងឯងប្រហែលជាគ្មាននរណាទាន់នឹកឃើញ រវៃតែទៅគិតអាណិតនាងតែពល់គ្នា អ្នកតូចអ្នកធំបណ្ដាដែលនៅក្នុងទីប្រជុំនោះជាច្រើន អត់មិនបាននាំគ្នាទឹកភ្នែកទៅតាមៗគ្នា វៀរលែងតែទុរយោធន៍ប៉ុណ្ណោះ ខ្ញុំចង់ដឹងណាស់ចិត្តថ្លើមវាដូចម្ដេចហ្ន៎ ។

យុធិស្ឋិរ អង្គុយស្ដាប់អនុជទាំងបួនសន្ទនាគ្នារហូតមកដល់វេលានេះ ដោយមិនចង់យល់ទាស់ តែអត់មិនបានទើបពោលជាផ្លូវប្រលោមចិត្តប្អូនថា កុំណា៎ កុំតូចចិត្តទៅថ្វី យើងបានស្បថទុកហើយថា នឹងធ្វើការកែកំហឹងវិញត្រាតែបាន ក្នុងឋាននេះក្សត្រិយ៍ យើងត្រូវតែដិបត្តិប-ការឲ្យសមដែលបានប្រណិធានទុកពល់មាត់ ទាំងនេះព្រោះកម៌របស់យើងៗ តោងទទួលសោយទុក្ខវេទនាអំពុលនេះ យើងនឹងគេចចៀសទៅឯណាក៏មិនរួច របស់ដែលត្រូវវិប័ត្ត ក៏ត្រូវតែវិប័ត្ត របស់ដែលវិ-ប័ត្តហើយសោត ក៏វិប័ត្តរួចទៅហើយ មុខងាររបស់យើងវេលានេះមានតែចៀសវាងភ័យ ពីងពួនមុខទៅតាមខសញ្ញាបន្តិចទៀតប៉ុណ្ណោះ សេចក្ដីលំបាកគោកយ៉ាករបស់យើង ក៏ស្បើយអស់ហើយ ។

ខសញ្ញា ដែលបាណ្ឌវក្សត្រិយ៍ត្រូវបដិបត្តិវេលានេះ ឈ្មោះថា

អស់ហើយ នៅតែត្រង់លាក់ខ្លួនពួនភ័យ រក្សាខ្លួនទុកឲ្យបាន លុះគិតឃើញដូច្នោះហើយ បាណ្ឌវកាត ក៏នាំគ្នាផ្លាស់ទីកន្លែងរឿយៗទៅចេញចាកទីនេះ ទៅកាន់ទីនោះដូចជាមនុស្សកំសត់ដើរដេកព្រៃក៏ប្រហែលគ្នា ការដែលគេចពួនចេញទៅដូច្នេះ រមែងមានភ័យជុំវិញខ្លួន រមែងនឿយលំបាកកាយជាធម្មតា ព្រោះមានសភាពជាធម្មតារបស់កាយតែងអន្ទោលទៅតាមកាយ នឹងបៀសវាងឲ្យផុតទៅមិនបាន គឺត្រូវកំដៅថ្ងៃ សេចក្ដីក្រហល់ក្រហាយស្រេកទឹកឃ្លានអាហារ សេចក្ដីនឿយព្រួយព្រះកាយពល ព្រះបាទដែលធ្លាប់តែទន់ត្រសូល ក៏ទៅជាក្រស់ក្រិនពុលពងបង្ហាមុគ ជំពប់ប៉ះបែកចេញលោហិត របស់អំបាលនេះជាទុក្ខវេទនា ពល់គ្រាដែលទ្រង់នាំគ្នាសញ្ជរពីត្រង់នេះទៅត្រង់ណោះ ៗ

វាមួយនោះ ទ្រង់យកអាវុធសម្រាប់អង្គ ទៅលាក់ទុកលើមែកឈើ ហើយនាំគ្នាចូលទៅកាន់ក្រុងវិរាដ ដើម្បីនឹងលាក់ខ្លួនពួនពីអាត្មានៅក្នុងក្រុងនោះ ឲ្យផុតភ័យន្ដរាយ ព្រោះហេតុថា តាមខសញ្ញាការទិរទេស បញ្ញត្តិទុកថា បើពួកគោរពទៅប្រទះឃើញខ្លួនក្នុងវេលាសន្យានេះសោត ពួកបាណ្ឌវនឹងត្រូវត្រឡប់ទៅដើរព្រៃជាថ្មីវិញ ១២ ឆ្នាំ ទៀត ខត្រង់នេះពួកបាណ្ឌវត្រូវបតិបត្តិនឹងប្រយ័ត្នអង្គឲ្យមែនទែនតាមការ ៗ

(មានតទៅទៀត)